# ទស្សនាវដ្ដីឃោសនា

ឯកសារ សំរាប់ ឃោសនិក

ការផ្សាយរបស់គណៈឃោសនាអប់រំមជ្ឈិម



លោកប្រធាន ហូ ជី មិញ អ្នកបង្កើតបក្សកុំមុយនីសឥណ្ឌូចិន
និងលោក អាចារ្យ មៀន អ្នកដឹកនាំដំបូងរបស់
បក្ស ប្រជាជនបដិវត្តកម្ពុជា

6
1983

សារនេះរួមមាន ៤ ផ្នែក

# ផ្នែក ទី ១

## ប្រភពកំណើតរបស់បក្សយើង

បក្សប្រជាជនបដិវត្តកម្ពុជា «មុននេះមានឈ្មោះថា បក្សប្រជាជនបដិវត្តខ្មែរ» បានចាប់បដិសន្ធិក្នុងមហាសន្និបាតលើកទី១ នាថ្ងៃទី២៨ មិថុនា ១៩៥១ ហើយបានបន្តនូវបុព្វហេតុតស៊ូបដិវត្ត ដ៏ត្រចះត្រចង់និងរុងរឿង ព្រមទាំងរក្សាប្រពៃណីដ៏ប្ដូរផ្ដាច់ របស់បក្សកុម្មុយនិស្តឥណ្ឌូចិន ។

នៅក្នុងសម័យ ដែលពួកអាណានិគមនិយមបារាំងឈ្លានពានលើទឹកដីកម្ពុជាយើង និងប្រទេសទាំងពីរជាភូមិផងរបងជាមួយយើងគឺវៀតណាម និង ឡាវ ពួកអាណានិគមនិយមបារាំង បានប្រើប្រាស់នូវឧបាយកលដ៏ពិសពុលជាច្រើន ក្នុងគោលបំណងបំបែកបំបាក់ប្រជាជននៃប្រទេសទាំងបី ដើម្បីងាយស្រួលអោយពួកវាត្រួតត្រា និង ជិះជាន់កេងប្រវ័ញ្ច ។

ដូចជាប្រជាជនវៀតណាម និងឡាវដែរ ប្រជាជនកម្ពុជាយើងបានក្រោកឡើង បង្កើតបានជាបណ្ដាចលនាស្នេហាជាតិ ដូចជាចលនាកុបកម្មរបស់ស៊ីវត្ថា អាចារ្យ-ស្វា ពោធិកំបោរ ប៉ត្រង់លឹង របស់ប្រជាជននៅបណ្ដាខេត្តជាច្រើន ដូចជា ខេត្តក្រចេះ កំពង់ចាម កំពង់ឆ្នាំង ។ល។ តស៊ូប្រឆាំងនឹងពួកអាណានិគមនិយម តែការតស៊ូនេះ ដោយខ្វះការដឹកនាំអោយបានត្រឹមត្រូវ ម៉្លោះហើយទីបំផុតក៏ត្រូវទទួលបរាជ័យ ។

→ ឆ្នាំ ១៩១៧ បដិវត្តន៍ខែតុលា ប្រទេសរុស្ស៊ីក៏បានផ្ទុះឡើងហើយសំរេចបាននូវជ័យជំនះជាស្ថាពរ ។ ក្រោយពន្លឺនៃបដិវត្តន៍ខែតុលា សមមិត្ត ង្វៀង អាយគ្វក គឺ «លោកប្រធាន ហូ ជី មិញ» ជាយុទ្ធជនកុំមុយនីសដំបូងគេបង្អស់ របស់វៀតណាម និង របស់ចលនាបដិវត្តន៍ នៃប្រទេសទាំងបីនៅឥណ្ឌូចិន បានបញ្ចេញកម្លាំង ឃោសនាផ្សព្វផ្សាយនូវលទ្ធិម៉ាក្សឡេនីនព្រមទាំងត្រៀមរៀបចំចាត់តាំង បង្កើតបក្សកុំមុយនីស ។ នៅថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ១៩៣០ ស.ម ង្វៀង អាយគ្វក ជំនួសមុខអោយអន្តរជាតិកុំមុយនីស បានបង្កើតឡើងនូវ

បក្សកុំមុយនីសឥណ្ឌូចិន ។ នៅខែមេសា ឆ្នាំ ១៩៣១ បក្សកុំមុយនីសឥណ្ឌូចិន ត្រូវបានទទួលស្គាល់ជាសាខាបក្សមួយរបស់អន្តរជាតិកុំមុយនីស ។ ចាប់តាំងពីពេលនោះមកបដិវត្តន៍របស់ប្រជាជន នៃប្រទេសទាំងបីបានផ្សារភ្ជាប់ជាមួយគ្នាយ៉ាងជិតស្និទ្ធ ហើយចលនាបដិវត្តប្រជាជនយើងក៏បានឈាន ចូលក្នុងតំណាក់កាលមួយថ្មី ។

ក្រោមការដឹកនាំរបស់បក្ស បណ្តាមូលដ្ឋានបដិវត្តនៃប្រទេសយើងបានរីកចំរើន និង ផ្ទុះឡើង នូវការតស៊ូរបស់កម្មករ កសិករ ដូចជាការតស៊ូរបស់កម្មករចំការកៅស៊ូនៅកំពង់ចាម ទាមទារបង្កើនប្រាក់បៀវត្ស បន្ថយម៉ោងធ្វើការ ទាមទារអោយមានសិទ្ធិសេរីភាព ក្នុងការបង្កើតអាជីវកម្ម ។ ចលនាតស៊ូរបស់កសិករនៅខេត្តបាត់ដំបងនិងរបស់ប្រជាជនព្នងនៅខេត្តក្រចេះ បានក្រោកឈរឡើងប្រឆាំង នឹង ការយកពន្ធដារ ។ល។

ឆ្នាំ ១៩៤៥ សហភាពសូវៀតបានវាយផ្តួលរំលំពួកហ្វាស៊ីសអាល្លឺម៉ង់ ជប៉ុន បដិវត្តន៍ខែសីហា ឆ្នាំ ១៩៤៥ របស់ប្រជាជនវៀតណាមបានផ្ទុះឡើង ហើយទទួលបានជ័យជំនះ ។ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម

បានបដិសន្ធិឡើងហើយជះឥទ្ធិពលយ៉ាងខ្លាំងក្លា ដល់ការតស៊ូរំដោះជាតិរបស់ប្រជាជនយើង ។ ដោយមានការជួយឧបត្ថម្ភរបស់បដិវត្តន៍វៀតណាម បណ្តាកម្លាំងបដិវត្តន៍នៅប្រទេសយើងបានកសាងនិងពង្រីកយ៉ាងឆាប់រហ័ស ។

នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៥០ សន្និបាតរណសិរ្សខ្មែរឥស្សរៈទូទាំងប្រទេស បានបង្កើតឡើងគណៈកម្មាធិការរណសិរ្សឯកភាពជាតិទូទាំងប្រទេស ដែលមាន ស.ម ទូ សាមុត ជាប្រធាននិងបង្កើតឡើងគណៈកម្មាធិការរំដោះជាតិមជ្ឈិមបណ្តោះអាសន្ន ដែលដឹកនាំដោយ ស.ម សឺង ង៉ុកមិញ ។

នៅថ្ងៃទី ១៩ ខែមេសា ឆ្នាំ ១៩៥០ លោកប្រធាន សឺង ង៉ុកមិញ ជំនួសមុខអោយគណៈកម្មាធិការរំដោះជាតិមជ្ឈិមបណ្តោះអាសន្ន អានសេចក្តីថ្លែងការណ៍ឯករាជ្យជូនប្រជាជនយើង និងសាធារណមតិបានប្រាប់ ដោយសារសំណូមពរនៃការវិវត្តន៍របស់បដិវត្តន៍ មហាសន្និបាតបក្សលើកទី ២ របស់បក្សកុម្មុយនិស្តឥណ្ឌូចិន « ខែកុម្ភៈ ឆ្នាំ១៩៥១ » សំរេចចាត់តាំងអោយមានបក្សបដិវត្តដោយឡែកនៅតាមប្រទេសនីមួយ ៗ ។

ដោយអនុវត្តតាមសេចក្តីសំរេចចិត្តនោះ នៅថ្ងៃទី ២៨ ខែ មិថុនា ១៩៥១ បណ្តាជនកុំមុយនីសកម្ពុជាបានបើកសម័យមហាសន្និបាតលើកទី ១ ហើយបង្កើតឡើងបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលមាន ស.ម ប្រធានសឺង ង៉ុកមិញ ជាប្រមុខ ទោះបីមានការបែងចែកបក្សជាបី តាមសភាពការណ៍រីកចំរើនរបស់ប្រទេសនីមួយ ៗ ក៏បក្សទាំងបី នៅបន្តជួយឧបត្ថម្ភគ្នាទៅវិញទៅមក ដោយឡែកគឺបក្សកុំមុយនីសវៀតណាម ដែលជាបក្សមួយខ្លាំងក្លាហើយរឹងមាំ បានបន្តកម្លាំងជួយពង្រឹងដល់បដិវត្តន៍កម្ពុជានិង បដិវត្តន៍ឡាវ ។ បក្សប្រជាជនបដិវត្តកម្ពុជា បក្សប្រជាជនបដិវត្តឡាវ និងបក្សកុំមុយនីសវៀតណាម មានប្រភពកំណើតតែមួយ គឺ បក្សកុំមុយនីសឥណ្ឌូចិនដែលមានមគ្គុទ្ទេសក៏រូបដឹកនាំគឺលោកប្រធានហូជីមិញ ។